# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២- ឯកឧត្តម សំ សារិត | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣- ឯកឧត្តម មុំ ស៊ីបុន | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៤- ឯកឧត្តម ឆា ឌុច | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ៥- ឯកឧត្តម ព្រហ្ម សិទ្ធត្រា | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦- ឯកឧត្តម សុខ ឡេង | អគ្គនាយកធនធានរ៉ែ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

| | | |
|---|---|---|
| ៧- ឯកឧត្តម សួន សិទ្ធី | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨- ឯកឧត្តម ណៅ ធូក | ប្រធានរដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- ឯកឧត្តម ថាច់ ឃន | អភិបាលខេត្តកំពត | សមាជិក |
| ១០- ឯកឧត្តម ថ្វាង សុផាន់ | អភិបាលរងរាជធានីភ្នំពេញ | សមាជិក |
| ១១- ឯកឧត្តម ម៉ៅ តិរុណ | អភិបាលរងខេត្តកណ្តាល | សមាជិក |
| ១២- ឯកឧត្តម ស៊ឹម សុខត្រី | អភិបាលរងខេត្តកំពង់ចាម | សមាជិក |
| ១៣- ឯកឧត្តម ចំន្ទ សំអាន | អភិបាលរងខេត្តសៀមរាប | សមាជិក |
| ១៤- ឯកឧត្តម ឆាំទ ហេមផាន | អភិបាលរងខេត្តកំពង់ឆ្នាំង | សមាជិក |
| ១៥- ឯកឧត្តម ឧួច សារុន | អភិបាលរងខេត្តកំពង់ស្ពឺ | សមាជិក |
| ១៦- ឯកឧត្តម ខូយ សុខា | អភិបាលរងខេត្តស្វាយរៀង | សមាជិក |
| ១៧- ឯកឧត្តម ស៊ុន សុខន | អភិបាលរងក្រុងព្រះសីហនុ | សមាជិក |
| ១៨- លោក ខាម ហ៊ុម | អភិបាលរងខេត្តព្រៃវែង | សមាជិក |
| ១៩- លោក ឌី គីមតុក | អភិបាលរងខេត្តពោធិសាត់ | សមាជិក |
| ២០- លោក សៀង ស៊ុតថន | អភិបាលរងខេត្តបាត់ដំបង | សមាជិក |
| ២១- លោក ធុន ត្រី | អភិបាលរងខេត្តក្រចេះ | សមាជិក |
| ២២- លោក ម៉ិន សំអុល | អភិបាលរងខេត្តកោះកុង | សមាជិក |
| ២៣- លោក គិន ណែត | អភិបាលរងខេត្តតាកែវ | សមាជិក |
| ២៤- លោក ជុំ ជាតិ | អភិបាលរងខេត្តឧត្តរមានជ័យ | សមាជិក |
| ២៥- លោក ឆាយ ទិត | អភិបាលរងខេត្តស្ទឹងត្រែង | សមាជិក |
| ២៦- លោក ឈុន ឈន់ | អភិបាលរងខេត្តកំពង់ធំ | សមាជិក |

មាត្រា ២.–

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានភារកិច្ចដូចតទៅ :

- ជាសេនាធិការផ្ទាល់របស់សម្តេចនាយករដ្ឋមន្ត្រី ដែលជាប្រមុខរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងតាមដានលើការធ្វើអាជីវកម្មខ្សាច់ ទាំងអាជីវកម្មនាំចេញ ទាំងអាជីវកម្មសម្រាប់ប្រើប្រាស់ក្នុងស្រុក
- ចុះសិក្សា និងកំណត់ទីតាំងតាមលក្ខណៈបច្ចេកទេសច្បាស់លាស់ មុននឹងអនុញ្ញាតឱ្យធ្វើអាជីវកម្ម ដោយចៀសវាងបាននូវមហន្តរាយផ្សេងៗ ដែលអាចកើតមានឡើង
- សិក្សាពីលទ្ធភាពបូមដី ទន្លេ ស្ទឹង ដើម្បីចាក់បំពេញបឹងបួរបម្រើដល់ការអភិវឌ្ឍក្នុងក្របខណ្ឌទូទាំងប្រទេស
- ពិនិត្យ និងលើកយោបល់សុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល ដើម្បីលុបចោលនូវអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវ-កម្មរបស់ក្រុមហ៊ុន អាជីវករ ដែលមិនអនុវត្តតាមការសម្រេចរបស់ គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់
- ធ្វើរបាយការណ៍ពីលទ្ធផលការងារដែលអនុវត្តបាន ជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងធនធានទឹក និងឧតុនិយម លើរាល់លិខិតស្នាម និងមានថវិកាដោយឡែកសម្រាប់ការងាររបស់ខ្លួន ដែលភ្ជាប់ទៅនឹងគណនីយរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**មាត្រា ៤.-**

គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ មានលេខាធិការដ្ឋានមួយ ជាជំនួយការការងារ ដែលមានទីតាំងនៅទីស្តីការក្រសួងធនធានទឹក និងឧតុនិយម ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយប្រធានមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងធនធានទឹក និងឧតុនិយម ឬជាមន្ត្រីក្របខ័ណ្ឌមកពីក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

**មាត្រា ៥.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់មានភារកិច្ចដូចតទៅ :

-ជាសេនាធិការឱ្យគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

-ទទួលរៀបចំផែនការការងារនិងកិច្ចប្រជុំរបស់គណៈកម្មាធិការ

-សម្របសម្រួល និងទំនាក់ទំនងជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់

-បំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់គណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ ។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីជនដូចក្នុងមាត្រា ១ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- ឯកសារ-កាលប្បវត្តិ